**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ...៤៤...សសរ

*រាជធានីភ្នំពេញ , ថ្ងៃទី១១ ខែ ធ្នូ ឆ្នាំ ១៩៩៨*

# សេចក្ដីសំរេច

## ស្ដីពីការផ្ទេរភារកិច្ច

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ ។
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- យោងតាមសំណូមពរការងារចាំបាច់របស់រាជរដ្ឋាភិបាល ។

## សំ រេ ច

**ប្រការ ១** : ផ្ទេរសិទ្ធិជូនឯកឧត្ដម **ស ខេង** ឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជា **នាយករដ្ឋមន្ត្រីស្ដីទី** នៃរាជរដ្ឋាភិបាល ជំនួសសម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលត្រូវអញ្ជើញទៅបំពេញទស្សនកិច្ចជាផ្លូវការ នៅសាធារណរដ្ឋសង្គមនិយមវៀតណាម ចាប់ពីថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ១៩៩៨ រហូតដល់សម្ដេចនាយក រដ្ឋមន្ត្រី អញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

**ប្រការ ២** : ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ខេត្ត-ក្រុង និង ឯកឧត្ដម ស ខេង ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

<u>ចម្លងជូន</u> :

- *ខុទ្ទកាល័យព្រះមហាក្សត្រ*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ២*
- *ឯកសារ-កាលប្បវត្តិ*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

//